សេចក្ដីក្លាហាន គឺជាការទទួលខុសត្រូវ

សេរីការ

លោក ហ៊ុន សែន បានអនុញ្ញាតឲ លោក កឹម សុខា ទៅចុះឈ្មោះបោះឆ្នោត ដើម្បី ទទួលផល ឬ លាងបាប ពីបុណ្យភ្ជុំបិណ្ឌរបស់ខ្លួនតាមប្រពៃណីពុទ្ធសាសនា និងបង្ហាញអំពីផលប្រយោជន៍ នៃរបៀបធ៌ម៌សន្ទនាដែលខ្លួនចង់បាន តែនៅក្នុងលក្ខខណ្ឌមួយ ដោយកាត់យល់បានថា គឺបន្ទាប់ពីចុះឈ្មោះរួចត្រូវរឹលត្រឡប់ចូលទៅឃុំខ្លួន នៅទីស្នាក់ការគណបក្សរិញ្ចាមព្រោះ លោក ហ៊ុន សែន គាត់ទុក ទីស្នាក់ការនោះ ជាគុកសិប្បនិម្មិត សំរាប់ លោក កឹម សុខា។ សេរីភាពនយោបាយ ក្នុងរយៈពេលដ៏ខ្លីបំផុតនេះ បើយើងយកវាមកពិនិត្យជាលំអិត មានលក្ខណៈវាជា ការបដិសេធ នៃឯលទ្ធិប្រជាធិតេយ្យ[1] (délit de démocratie) ព្រោះថាទាំងខាង លោក ហ៊ុន សែន និង លោក កឹម សុខា ក៏ដែរ គាត់សម្រុះសម្រួលគ្នា បំពានលទ្ធិប្រជាធិបតេយ្យ ដើម្បីរក ប្រយោជន៍រៀងខ្លួន៖ លោកហ៊ុន សែន យកច្បាប់មកលេងសើចតាមតែចិត្តខ្លួនចង់បាន ដើម្បី បំរើប្រយោជន៍អាត្មា ចំណែកលោក កឹម សុខា ទទួលយល់ព្រមយក លក្ខខណ្ឌខុសច្បាប់ មកធ្វើជា ដំណោះស្រាយបង្ហន[2] (solution différée) ដើម្បី បំពេញចិត្ត លោក ហ៊ុន សែន ដែលវា ផ្ទុយនឹងសេចក្ដីក្លាហានរបស់គាត់ បង្ហាញឲឃើញមកដល់សព្វថ្ងៃនេះ គឺហ៊ានប្រឆាំងនឹងតុលាការ បម្រើអយុត្ដិធ៌ម ដោយប្រើ មធ្យោបាយអហិង្សា មិនគោរពអំណាចច្បាប់អយុត្ដិធ៌ម (Désobéissance civile)។

---

[1] ការបដិសេធនៃលទ្ធិប្រជាធិបតេយ្យ; ការបណ្ដោយឲខូចខាតដល់តម្លៃលទ្ធិប្រជាធិបេតយ្យ។

[2] ដំណោះស្រាយបង្ហន; ដំណោះស្រាយដែលលើកទៅពេលក្រោយ។

ការសម្រុះសម្រួលបែបនេះ គឺ លោក កឹម សុខា គាត់ មមុល ជាទម្លាប់ ចូលទៅក្នុងអន្ទាក់មរណារបស់ លោក ហ៊ុន សែន ជានិច្ច ប្រែរូបភាពនៃសេចក្ដីក្លាហានជាប្រតិពលរបស់គាត់ ជាការមិនទទួលខុសត្រូវ ក្នុងហាន:ជា ប្រមុខនៃបក្សប្រឆាំង ដើម្បីប្ដូរបាន នូវអំណាចដឹកនាំជាតិ។ យើងសង្កេតឃើញថា ក្រាណា ជោគជ័យ នៃលទ្ធិប្រជាធិបតេយ្យ បើកទ្វារ ជូនដល់ប្រជាពលរដ្ឋខ្មែរ បែរជាអ្នកដឹកនាំបក្សប្រឆាំង ប្រញាប់ប្រញាលនាំគ្នាទៅបិទទ្វារ នៃសេចក្ដីសង្ឃឹមនោះជាបន្ទាន់។ សព្វថ្ងៃពួកគាត់លែងហ៊ានប្រើពាក្យ « ប្ដូរអ្នកដឹកនាំជាតិសព្វថ្ងៃ » បែរជា យកពាក្យ « សហការជាមួយពួកនោះ » មកប្រើជំនួសវិញ ដើម្បីអាចថតរូបខ្លួន ពាក់អាវធំ ចង ក្រាវ៉ាត នៅរដ្ឋសភា ជាឯកឧត្តម ជាប្រធានគណកម្មការនេះនោះ ផ្សាយក្នុង Facebook សរសេរទ្រឹស្ដី ភ្ជាប់ប្រជាពលរដ្ឋ ថាខ្លួនកំពុងគិតពី ចមនយោបាយជាតិ (haute politique nationale) ហាក់បីដូចជារាស្ត្រ ល្ងង់ខ្លៅណាស់ មើលមារយាទខ្ជិចចង្រៃដល់ជាតិរបស់ពួកខ្លួនមិនឃើញ។ កុំភ្លេចថា ពាក់ស្បង់ មិនមែនសុទ្ធជាមានចិត្ត ជាសង្ឃនោះឡើយ ដូចពាក់អាវធំ មិនមែនសុទ្ធជាវរជននោះដែរ។

រាល់ពេលណា ពួកគាត់ មានជម្លោះជាមួយពួកអ្នកកាន់អំណាច ដែលជា ក្ដី (collègue) របស់ពួកគាត់ គាត់នាំគ្នា ស្រែកហៅប្រជារាស្ត្រឲជួយគាត់ តែនៅពេលណាដែល លោក ហ៊ុន សែន ចង់ជា ជាមួយពួកគាត់វិញ គាត់នាំគ្នានិយាយថា ខ្មែរយើង ស្ដាប់ពាក្យគាត់និយាយមិនយល់។ ការណ៍នេះហើយ ដែល គេហៅថា សេចក្ដីក្លាហាន មិនមានការទទួលខុសត្រូវ។ តែ លោក កឹម សុខា សោកី ត្រូវយល់ថា ការសម្រុះសម្រួលសព្វថ្ងៃ វាមិនមែនជា ដំណោះស្រាយជាស្ថាពរ ដល់បញ្ហារបស់គាត់នោះឡើយ ព្រោះគាត់នៅតែជាប់ទ្រុងធ្យាប់ លោក ហ៊ុន សែន សុខេធិក ជានិច្ច។ ការណ៍នេះ វាគ្មានអ្វីពិបាកនឹងយល់នោះទេ ព្រោះវា ជាមធ្យោបាយ ចំណាន ជាប្រក្រតីរបស់ លោក ហ៊ុន សែន តែប៉ុណ្ណោះ॥